YUNNAN DAILY PRESS GROUP
云南日报报业集团
No.120

ប្រទេសចិន-ខេត្តយូនណាន

ទស្សនាមន្លាវ៉ា ប្រចាំថ្ងៃ

YUNNAN DAILY PRESS GROUP
english.yunnan.cn

ឆ្នាំទី 25 លេខ 7405 ថ្ងៃសុក្រ ទី 11 ខែ សីហា ឆ្នាំ 2017

ផលិតកម្មទឹកដោះគោចិនកំពុងតែត្រូវបានពង្រឹងគុណភាព ផ្នែកតាមទស្សនៈ "គុណភាពកាន់តែខ្ពស់កាន់តែល្អ"

ដោយ ខឹ ជុងចា (ដកស្រង់ចេញពី "ការសែតប្រជាជន ដេលី")

នៅក្នុងតំបន់ស្វ៊ីយយ៉ាត ហ្គានណានទីប៉ៃ ខេត្ត ហ្គានស៊ូ នៅភាគពាយ័ព្យនៃ ប្រទេសចិន ឧស្សាហកម្ម ផលិតទឹកដោះគោ កំពុងតែក្លាយជាប្រភពចំណូល ដ៏ចំបងសម្រាប់កសិករ នៅក្នុងមូលដ្ឋាន (រូបថត ដោយ Chen Bin)

ពេលនេះ យើងខ្ញុំសូមបន្ត និទាន "រឿងចិន" ជូនលោកអ្នកដើម្បីឧទ្ទេសនាមអំពីកំណែទម្រង់ផ្នែកផ្គត់ផ្គង់របស់ប្រទេសចិន និងផ្សព្វផ្សាយអំពីដំណើរងើបឡើងវិញនៃផលិតកម្មទឹកដោះគោរបស់ប្រទេសចិន ។

សព្វថ្ងៃ ប្រជាជនចិនយកចិត្តទុកដាក់កម្រិតខ្ពស់ចំពោះការថែរក្សាសុខភាព ហើយមានសំណូមពរ និងតម្រូវការកាន់តែច្រើនអំពីការលើកកម្ពស់គុណភាព និងបង្កើនប្រភេទផលិតផលដោះគោ ។ លោកស្រី លី ជឺ អ្នកគ្រប់គ្រងផលិតកម្មម្នាក់ របស់ក្រុមហ៊ុនពន្លឺរស្មីផលិតកម្មទឹកដោះគោ ១ន់តាសាន ខេត្តហ៊ីឡុងជាំង បានធ្វើការងារនេះ១៦ឆ្នាំហើយ ។ លោកស្រីធ្លាប់ឆ្លងកាត់ដោយផ្ទាល់នូវដំណើរវិវឌ្ឍន៍ដែលប្រែក្លាយពីការចិញ្ចឹមសត្វគោបែបធម្មជាតិទៅជាវិធីចិញ្ចឹមបែបវិទ្យាសាស្ត្រ ហើយជាអ្នកសាក្សីនៃការងើបឡើងវិញនៃផលិតកម្មទឹកដោះគោរបស់ប្រទេសចិន ។

លោកស្រីធ្វើការងារនេះបាន ១៦ឆ្នាំហើយ ។ លោកស្រីយល់ឃើញថា អ្នកដែលចង់ធ្វើការងារនេះឱ្យបានល្អសុទ្ធតែផ្តោតសំខាន់ទៅលើការ ចិញ្ចឹមសត្វគោ ដើម្បីយកទឹកដោះគោ ល្អបំផុត ដោយមានពាក្យស្លោកមួយ ម៉ាត់ថា "គុណភាពកាន់តែខ្ពស់កាន់តែល្អ" ។

លោកស្រីចូលធ្វើការនៅកសិដ្ឋានចិញ្ចឹមសត្វគោ បន្ទាប់ពីបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ ។ លោកស្រីបានរំលឹកឡើងវិញថា កាលនោះគេមិនគិតពីអាកាសធាតុ ឬបរិស្ថានសម្រាប់ចិញ្ចឹមសត្វគោទេ ពីព្រោះមានវាលស្មៅទូលំទូលាយ ហើយមានមនុស្សរស់នៅទីនោះមិនច្រើនទេ បានជាយើងចិញ្ចឹមសត្វគោបែបធម្មជាតិ ។

ក្រោយពីធ្វើការបានមួយឆ្នាំ លោកស្រីបានក្លាយជាបុគ្គលិកការងារម្នាក់ក្នុងការិយាល័យគ្រប់គ្រងគម្រោងប្រភពទឹកដោះគោ ។ លោកស្រីចាប់ផ្តើមសិក្សាស្រាវជ្រាវអំពីប្រភពទឹកដោះគោ ហើយទើបដឹងថា កសិដ្ឋានចិញ្ចឹមសត្វគោដែលលោកស្រីធ្លាប់ធ្វើការនោះ ស្ថិតនៅក្នុងតំបន់ដែលមានលក្ខខ័ណ្ឌល្អបំផុតសម្រាប់ចិញ្ចឹមសត្វគោ ពោលគឺស្ថិតនៅតំបន់ក្នុងចន្លោះរយៈបណ្តាយ ខាងជើង៤២-៤៧អង្សាសេ។ លោកស្រីបញ្ជាក់ថា នេះជាឧត្តមភាពពិសេសមួយ បើមិនអាចប្រើប្រាស់វាឱ្យបានសត្វគ្រប់ពិតជាគួរឱ្យស្តាយណាស់ ។

ក្រោយមក ដើម្បីចិញ្ចឹមសត្វគោឱ្យបានកាន់តែល្អប្រសើរ និងទទួលបានទឹកដោះគោដែលកាន់តែមានជីវជាតិ និងរសជាតិឆ្ងាញ់ គេចាប់ផ្តើមផ្តល់បន្ទប់VIP ដល់សត្វគោ។ ជាពិសេសក្នុងកសិដ្ឋានចិញ្ចឹមគោធំៗ សត្វគោតែងតែទទួល "បដិសណ្ឋារកិច្ចយ៉ាងរាក់ទាក់ កក់ក្តៅ" ដោយអាចស៊ីចំណីដែលមានជីវជាតិ និងទឹកដែលមានកម្តៅនឹងនរ ហើយអាចស្តាប់ភ្លេងពីរោះ និងអាចដេកលើពួកទន់ៗ ។ ចំណែកការយកទឹកដោះគោ គេក៏ធ្វើតម្រាប់តាមរបៀបធម្មជាតិដូចបំបៅកូនគោអីចឹង ។

លោកស្រីបន្តទៀតថា គុណភាព គឺជាជីវិតរបស់ផលិតផលទឹកដោះគោ ។ ខ្ញុំយល់ឃើញថា គុណភាពផលិតផលហាក់ដូចជាក្មេងម្នាក់ ដែលងាយកើតជំងឺ មានតែខិតខំថែទាំវាឱ្យបានម៉ត់ចត់ ទើបវាអាចធំធាត់ឡើងដោយមានសុខភាពល្អ ។

លោកស្រីសង្កត់ធ្ងន់ថា សព្វថ្ងៃក្មេងៗរើសអើងចំណី យុវជន យុវតី ចូលចិត្តផលិតផលដែលមានកម្រិតថ្នាក់ខ្ពស់ ចំណែកចាស់ៗមានតម្រូវការកាន់តែច្រើន ។ ដូច្នេះផលិតកម្មរបស់យើងត្រូវតែបោះជំហានទៅមុខឱ្យទាន់ពេលវេលា ។ បើពុំនោះទេ តើអ្នកណាសុខចិត្តទិញផលិតផលរបស់យើង? ។

ផ្សិតដើមស្រល់ខេត្តយូនណាន មានប្រជា-ប្រិយភាពនៅក្រុងប៉េកាំងសៀងហៃ និងក្វាងចូរ

ការលក់និងទិញផលិតផល ផ្សិតដើមស្រល់ នៅក្នុងខេត្ត យូណាន (រូបថត ដោយ Yang Zheng)

ផ្សិតដើមស្រល់ជាផ្សិតមួយប្រភេទ ដែលដុះនៅក្រោមដើមស្រល់ ។ ខែនេះជាខែដែលប្រមូលផលផ្សិតដើមស្រល់នេះនៅខេត្តយូនណាន ។ ជារៀងរាល់ថ្ងៃ ផ្សិតដើមស្រល់យូនណានជាង ១០០ តោនបានត្រូវលក់ដូរក្នុងតម្លៃ ៣០០ យ័ន/គីឡូក្រាមតាមទីផ្សារ ។ ផ្សិតដើមស្រល់យូនណានមិនគ្រាន់តែបានត្រូវដឹកជញ្ជូនទៅដល់ក្រុងប៉េកាំង សៀងហៃ ហាងចូរ ក្វាងចូរ និងក្រុងធំផ្សេងៗ ទៀតរបស់ប្រទេសចិនប៉ុណ្ណោះទេ ថែមទាំងបានត្រូវនាំចេញទៅកាន់ទីផ្សារនៃប្រទេសអឺរ៉ុប អាមេរិក ជប៉ុន និងកូរ៉េខាងត្បូងទៀតផង ។

សព្វថ្ងៃ ខេត្តយូនណានជាខេត្តដែលនាំចេញផ្សិតដើមស្រល់ច្រើនជាងគេក្នុងប្រទេសចិនដោយមិនគ្រាន់តែដណ្តើមបានទីផ្សារក្នុងស្រុកច្រើនជាងគេក្នុងប្រទេសចិនប៉ុណ្ណោះទេ ហើយមានទំហំនាំចេញស្មើនឹង៧០ភាគរយ នៃទំហំនាំចេញសរុបរបស់ប្រទេសចិន ។ មិនតែប៉ុណ្ណោះ ផ្សិតដើមស្រល់ខេត្តយូនណាន ដែលនាំចេញទៅប្រទេសជប៉ុនមានទំហំស្មើនឹង៤០ភាគរយ នៃការនាំចូលផ្សិតដើមស្រល់របស់ប្រទេសជប៉ុន ។ គួរបញ្ជាក់ថា ផ្សិតដើមស្រល់បានក្លាយជាផលិតផលផ្សិតព្រៃដែលមានលក្ខណៈតំណាងរបស់ខេត្តយូនណានសម្រាប់ នាំ ចេញ ទៅ ក្រៅ ប្រទេស ។

សកម្មភាពរួមគ្នាយាមល្បាត និងអនុវត្តន៍ច្បាប់តាមទន្លេមេគង្គ ចិន-ឡាវ-មីយ៉ាន់ម៉ា-ថៃលើកទី៦០សម្រេចដោយជោគជ័យ

ដោយ យ៉ាង ជឹង (អត្ថបទពីទីភ្នាក់ងារព័ត៌មានស៊ីនហ្គូចិន)

ប៉ុន្មានថ្ងៃមុន នាវាអនុវត្តន៍ច្បាប់ ៣គ្រឿងរបស់ប្រទេសចិនបានត្រឡប់មកដល់កំពង់ផែក្វាន់ឡីរបស់ប្រទេសចិនវិញ ។ នេះជានិមិត្តសញ្ញាដែលសកម្មភាពរួមគ្នាយាមល្បាត និងអនុវត្តន៍ច្បាប់តាមទន្លេមេគង្គចិន-ឡាវ-មីយ៉ាន់ម៉ា-ថៃលើកទី ៦០ បានត្រូវសម្រេចដោយជោគជ័យ ។

សកម្មភាពអនុវត្តន៍ច្បាប់នេះមានរយៈពេល ៥ថ្ងៃ ៤យប់ ។ ប្រទេសទាំង៤ ចិន ឡាវ មីយ៉ាន់ម៉ា និងថៃបានចាត់បញ្ជូននាវាអនុវត្តន៍ច្បាប់ ៨គ្រឿង និងអ្នកអនុវត្តន៍ច្បាប់២១៥នាក់ ដោយបានធ្វើនាវាចរណ៍អស់រយៈពេល ៤១ ម៉ោងនិងធ្វើដំណើរបាន ៥៩៥គីឡូម៉ែត្រ។ ភាគីនានាបានរួមគ្នាពិនិត្យនាវា ១១គ្រឿង នាវិក ៤៧នាក់ និងទំនិញ ៣៦០តោន ។

តាមការឧទ្ទេសនាមបានឱ្យដឹងថា ក្បួននាវាអនុវត្តន៍ច្បាប់ បានបំពេញការងារច្រើនក្នុងតំបន់"ត្រីកោណមាស" និងតំបន់សំខាន់មួយចំនួនទៀត រួមមានការរួមគ្នាពិនិត្យនាវា និងសង្គ្រោះបន្ទាន់អ្នកជំងឺជាដើម ដែលបានជួយពង្រឹងសមត្ថភាពរួមគ្នាដោះស្រាយបញ្ហាផ្សេងៗក្នុងតំបន់ ។

បេតិកភណ្ឌវប្បធម៌អ្ករបីចិនត្រូវដាក់តាំងបង្ហាញនៅក្រសួងការពារជាតិកម្ពុជា

ដោយ ម៉ាវ ភីងហ្ស៊ី (អត្ថបទពីទីភ្នាក់ងារព័ត៌មានស៊ីនហ្គូចិន)

ពេលថ្មីៗនេះ ពិព័រណ៍បេតិកភណ្ឌវប្បធម៌អ្ករបីចិនក្រោមប្រធានបទ "បន្តផ្សព្វផ្សាយ និងច្នៃប្រឌិត" បានរៀបចំនៅក្នុងក្រសួងការពារជាតិកម្ពុជា ដែលបានធ្វើឱ្យទាហានខ្មែរទទួលបានការយល់ដឹងដោយផ្ទាល់អំពីបេតិកភណ្ឌវប្បធម៌អ្ករបីរបស់ប្រទេសចិន ។

ពិព័រណ៍នេះជាសកម្មភាពសំខាន់មួយដែលរៀបចំក្នុងឱកាស "សប្តាហ៍វប្បធម៌អ្ករបីចិន" និងបានដាក់តាំងបង្ហាញនូវវត្ថុសិល្ប:ដ៏មានតម្លៃច្រើនរបស់ប្រទេសចិនរួមមានក្រណាត់ប៉ាក់រាជ-វង្សហាន ការកាត់ក្រដាស និងរូបសួនជាដើមហើយបានទាក់ទាញទាហានខ្មែរច្រើនមកទស្សនា ។ ទន្ទឹមនឹងនេះគេបានរៀបចំសកម្មភាពធ្វើបទបង្ហាញអំពីឧបករណ៍តន្ត្រីជ្លងតូចធំបុរាណចិនក្នុងសាលប្រជុំដែលបានទទួលការចាប់អារម្មណ៍យ៉ាងខ្លាំងពីទាហានខ្មែរដោយគ្មានកន្លែងអង្គុយណាមួយសល់ទេ ។

មន្ត្រីនៃក្រសួងការពារជាតិកម្ពុជាមានប្រសាសន៍ថា ប្រទេសកម្ពុជានិងចិនបានបង្កើតកិច្ចសហប្រតិបត្តិការស្និតស្នុត ហើយសង្ឃឹមថា ពិព័រណ៍នេះនឹងអាចធ្វើឱ្យទាហានខ្មែរមានការយល់ដឹងកាន់តែច្រើនអំពីវប្បធម៌ចិន។

គម្រោងផលិតអគ្គិសនីដោយកម្តៅក្រោមដីរបស់ក្រុមហ៊ុនឌីមេធីដំណើរការសាកល្បងដោយជោគជ័យ

ដោយ យ៉ាង ស្ទ្រី យ៉ាន
ដោយ: យ៉ាង ជឹង

ពេលថ្មីៗនេះ ម៉ាស៊ីនផលិតអគ្គិសនីកម្លាំង ១ មេហ្គាវ៉ាត់ ដែលជាគម្រោងដំណាក់កាលទី ១ នៃ"គម្រោងផលិតអគ្គិសនីដោយកម្តៅក្រោមដីកម្លាំង ១០០មេហ្គាវ៉ាត់នៅក្រុងយូយលី" របស់ក្រុមហ៊ុនថាមពលថ្មី ឌីមេធី ក្រុង ជឹងចូវ បានដំណើរការសាកល្បងជាលើកដំបូងដោយជោគជ័យ ។ នេះជាការច្នៃប្រឌិតដ៏សំខាន់របស់ប្រទេសចិនក្នុងការសិក្សាស្រាវជ្រាវអំពីគ្រឿងបរិក្ខារផលិត អគ្គិ-សនីដោយកម្តៅក្រោមដីនិងការអភិ-វឌ្ឍធនធានថាមពលកម្តៅក្រោមដី ។

តាមការឧទ្ទេសនាមបានឱ្យដឹងថា កម្តៅក្រោមដីជាធនធានមួយប្រភេទដែលមានបរិមាណធំ និងត្រូវបង្កប់នៅតំបន់ដ៏ច្រើន ហើយមានលក្ខណៈពិសេសច្រើនដូចជាអាចថែរក្សាការពារបរិស្ថានប្រើប្រាស់នៅក្នុងវិស័យច្រើន មានភាពនឹងនរ និងអាចប្រើប្រាស់ជាថ្មីឡើងវិញជាដើម ។ បន្ទាប់ពីឆ្នាំ ២០០៩រៀងមក ក្រុមហ៊ុនថាមពលថ្មី ឌីមេធី ក្រុងជឹងចូវបានខិតខំសិក្សាស្រាវជ្រាវអំពីបច្ចេកទេសគន្លឹះសម្រាប់ផលិតអគ្គិសនីដោយកម្តៅក្រោមដី ហើយបានកែសម្រួលគ្រឿងបរិក្ខារ និងបង្កើតរូបភាពថ្មីសម្រាប់ផលិតអគ្គិសនីដោយប្រើប្រាស់ធនធានកម្តៅក្រោមដី ។ មិនតែប៉ុណ្ណោះ ក្រុមហ៊ុនបានទទួលការជោគជ័យក្នុងការច្នៃប្រឌិតប្រព័ន្ធស្វ័យប្រវត្តិកម្រិតខ្ពស់ ដែលអាចផ្តាច់អគ្គិសនីដោយស្វ័យប្រវត្តិនៅពេលកើតមានស្ថានភាពមិនប្រក្រតី ។

ម៉ាស៊ីនខួងដីរឹងដែលមានវិជ្ជមាត្រធំជាងគេក្នុងប្រទេសចិនត្រូវផលិតដោយជោគជ័យនៅក្រុងគុនមីង

ដោយ ចឹង យ៉ីឈួន (អត្ថបទពីទីភ្នាក់ងារព័ត៌មានស៊ីនហ្គូចិន)

នៅថ្ងៃទី១ ខែសីហា ឆ្នាំ ២០១៧ ម៉ាស៊ីនខួងដីរឹងសញ្ញា "ពពកចម្រុះពណ៌" (TBM) ដែលសិក្សាស្រាវ-ជ្រាវដោយប្រទេសចិន និងមានវិជ្ជ-មាត្រធំជាងគេក្នុងប្រទេសចិនបានត្រូវផលិតដោយជោគជ័យនៅក្នុងរោងចក្រនៅក្រុងគុនមីងរបស់ក្រុមហ៊ុនផលិតកម្ម អគ្គិសនីគ្រុប ប្រទេសចិន ។

លោកហ៊ីហ្ស៊ីអនុប្រធានវិទ្យាស្ថានសិក្សាស្រាវជ្រាវនៃក្រុមហ៊ុនផលិតគ្រឿងបរិក្ខារផ្លូវដែកគ្រុប ប្រទេសចិនបានឧទ្ទេសនាមថា ម៉ាស៊ីន ខួងដីរឹងសញ្ញា "ពពកចម្រុះពណ៌" នេះបានបំពាក់ដោយកាំបិតខួងដីដែលមានវិជ្ជមាត្រ ៨,០៣ ម៉ែត្រ ។ វាជាម៉ាស៊ីន ខួងដីរឹងដែលមានវិជ្ជមាត្រធំជាងគេ ក្នុងប្រទេសចិន ។ លោកបន្តទៀតថា ម៉ាស៊ីនខួងដីរឹងនេះបានប្រើប្រាស់បច្ចេកទេសច្នៃប្រឌិតថ្មីដ៏ច្រើនដូចជារចនាសម្ព័ន្ធឆ្អឹងដែកទ្រ-ទ្រង់ និងដែយន្ត្រពិសេសជាដើមដើម្បីដោះស្រាយបញ្ហាផ្សេងៗក្នុងការខួងដី ។

តាមការឧទ្ទេសនាមពីអ្នកទទួលខុសត្រូវនៃក្រុមហ៊ុនដឹកផ្លូវក្រោម ដីគ្រុប ប្រទេសចិនបានឱ្យដឹងថា ម៉ាស៊ីនខួងដីរឹងសញ្ញា "ពពកចម្រុះពណ៌" នឹងត្រូវប្រើប្រាស់សម្រាប់ជីករូងក្នុងភ្នំ ការលីកុងសម្រាប់សាងសង់ផ្លូវដែកពីក្រុងតាលីទៅក្រុងយូយលីនៃខេត្ត យូនណាន ។

ម៉ាស៊ីនខួងដីរឹង ដែលនឹងត្រូវ ប្រើប្រាស់សម្រាប់ខួងដីតាមបណ្តោយ ច្រកមួយ នៃគម្រោងកសាងផ្លូវដែក ដាលី-រូអ៊ីលី នៅក្នុងខេត្តយូណាន (រូបថតពីស៊ីនហ្គូ ដោយ Jing Huihui)